ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC



គសវ

Work Activities

ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ | ១ |
| ២- | សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតងនិងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងសម្រាប់រយៈពេល១០ឆ្នាំ | ៣ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១២ | ៥ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ |

## សេចក្តីព្រាងគោលនយោបាយជាតិស្តីពី

# ប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ

កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **តាំង គុងហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រុមប្រឹក្សាគោលនយោបាយដីធ្លី។



សេចក្តីព្រាងគោលនយោបាយនេះ តាក់តែងឡើងដោយផ្អែកលើឯកសារបឋមនៃក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលឆ្នាំ២០០៦និងសេចក្តីថ្លែងការណ៍លេខ២៧ សជណ អក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លីដែលចែងតម្រូវឲ្យរៀបចំប្រព័ន្ធវាយតម្លៃថ្លៃដីមួយមានតម្លាភាព និងការទទួលស្គាល់ជាផ្លូវការ សម្រាប់បម្រើវិស័យសាធារណៈនិងវិស័យឯកជនទៅតាមលំនាំនិងបទពិសោធខ្លះៗនៃប្រទេសនានា ផ្សារភ្ជាប់នឹងសភាពការណ៍ជាក់ស្តែងនៃការវាយតម្លៃថ្លៃអចលនទ្រព្យរបស់ប្រទេសយើងដែលកំពុងដឹកនាំប្រតិបត្តិដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ ដោយមានការគាំទ្រពីអង្គការស៊ីដាកាណាដា បានសហការធ្វើការសិក្សានៅតំបន់មួយចំនួននៃរាជធានីភ្នំពេញ និងក្រុងព្រះសីហនុ និងបានរៀបចំសិក្ខាសាលាស្វែងយល់នូវគោលគំនិតសំខាន់ៗសម្រាប់ការកសាងជាឯកសារមូលដ្ឋាន។ ក្នុងចន្លោះឆ្នាំ២០០៨ និង២០០៩ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានរៀបចំជាសេចក្តីព្រាងឯកសារបឋមនៃគោលនយោបាយស្តីពីការវាយតម្លៃថ្លៃដីនិងបានធ្វើការកែលម្អជាបន្តបន្ទាប់ជាមួយមន្ត្រីបង្គោលនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ក្នុងឆ្នាំ២០១០។ ក្នុងឆ្នាំ២០១១

សេចក្តីព្រាងចុងក្រោយត្រូវបានធ្វើការពិគ្រោះយោបល់ជាមួយតំណាងក្រសួង/ស្ថាប័នពាក់ព័ន្ធ ដោយមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជននិងសង្គមស៊ីវិល និងជាពិសេសមានការពិភាក្សាជាច្រើនលើកនៅចុងឆ្នាំ២០១១និងដើមឆ្នាំ២០១២ ជាមួយតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាស្ថាប័នអនុវត្តផ្ទាល់។

គោលនយោបាយវាយតម្លៃថ្លៃអចលនទ្រព្យមានសារៈសំខាន់ណាស់ក្នុងការផ្តល់ទិសដៅការងារដែលត្រូវអនុវត្ត ដើម្បីឈានទៅបង្កើតបានជាប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យមួយមានវិសាលភាពទូលំទូលាយ សម្រាប់បម្រើសេចក្តីត្រូវការរបស់វិស័យសាធារណៈ និងវិស័យឯកជននិងធានានូវទីផ្សារដីធ្លីមួយមានប្រសិទ្ធភាព និងតម្លាភាព។ ដូច្នេះការរៀបចំឲ្យមានប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ គឺជាការឆ្លើយតបទៅនឹងរបត់នយោបាយ សង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសជាតិដែលកាន់តែរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ក្នុងបរិបទនៃសេដ្ឋកិច្ចទីផ្សារ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ក្រោយពីបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។

## សេចក្តីព្រាងគោលនយោបាយជាតិស្តីពី
# ការអភិវឌ្ឍបៃតង
## និងផែនការយុទ្ធសាស្ត្រជាតិស្តីពី
# ការអភិវឌ្ឍបៃតងសម្រាប់រយៈពេល១០ឆ្នាំ

កាលពីថ្ងៃទី៧ និងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ វេលាម៉ោង៨:៣០នាទីនិងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ សំអាត** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងសម្រាប់រយៈពេល១០ឆ្នាំ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង។



ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងបានរៀបចំសេចក្តីព្រាងឯកសារគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតងនិងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងសម្រាប់រយៈពេល១០ឆ្នាំ ដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង ដោយផ្តោតលើប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ ចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ចដោយគិតគូរបន្ថែមលើការលើកទឹកចិត្តបៃតងដូចជា ពន្ធបៃតង ហិរញ្ញវត្ថុបៃតង ពិសេសឥណទានបៃតង មីក្រូហិរញ្ញវត្ថុបៃតង និងវិនិយោគទុនបៃតងដល់ប្រជាជន ដោយធ្វើឲ្យមានការរីកចម្រើន បង្កើនគុណភាពជីវិត បង្កើតឱកាសការងារបៃតងដល់ប្រជាជន និងធ្វើឲ្យមានសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី តាមរយៈការអភិវឌ្ឍបៃតង ដែលជួយរក្សាប្រព័ន្ធអេកូឡូស៊ីភពផែនដី ឲ្យមានតុល្យភាពជាមួយនឹងសមត្ថភាពទ្រទ្រង់ជីវិតរបស់ភពផែនដី។

ការសម្រេចបាននូវការអភិវឌ្ឍបៃតងនិងការអភិវឌ្ឍដោយចីរភាពរបស់កម្ពុជា ដោយផ្អែកលើភាពជោគ

ជ័យនៃគោលនយោបាយ “ឈ្នះ-ឈ្នះ” របស់សម្តេចតេជោនាយករដ្ឋមន្ត្រី និងកំណើនសេដ្ឋកិច្ចសង្គម វប្បធម៌ ចេញពីការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ជាសំខាន់បានជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដោយឈរលើគោលការណ៍អភិវឌ្ឍបៃតងនិងសេដ្ឋកិច្ចបៃតងពិភពលោក រួមជាមួយកិច្ចការពារបរិស្ថានជាស្នូលនៃការអភិវឌ្ឍឲ្យក្លាយទៅជាការអភិវឌ្ឍបៃតងគំរូក្នុងពិភពលោក។ ការអភិវឌ្ឍសេដ្ឋកិច្ចមានដំណើរការឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង ដោយដើរស្របពេលជាមួយគ្នានឹងការថែរក្សាគុណភាពបរិស្ថាន ការលើកកម្ពស់សុខភាពសាធារណៈ ការជំរុញប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គម ស្របតាមយុទ្ធសាស្ត្រចតុ-កោណដំណាក់កាលទី២ ក្នុងការអភិវឌ្ឍប្រទេសលើគ្រប់វិស័យនិងការកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាពខ្ពស់ដែលស្របនឹងចរន្តគោលនយោបាយសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិនិងបណ្តាប្រទេសក្នុងពិភពលោក ដោយធានាបាននូវស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សន្តិភាព ការអភិវឌ្ឍប្រកបដោយចីរភាព។

គោលដៅអភិវឌ្ឍន៍ដោយចីរភាពផ្អែកលើបង្គោលគ្រឹះ៤គឺ សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង សុខភាពសាធារណៈ គុណភាពបរិស្ថាន ជីវភាពរស់នៅរបស់ប្រជាជន និងរក្សាអត្តសញ្ញាណវប្បធម៌ជាតិ ដែលជាកាតាលីករទាក់ទាញវិនិយោគិនបរទេសជាច្រើនលើការអភិវឌ្ឍបៃតង លើវិស័យកសិកម្មបៃតង ឧស្សាហកម្មបៃតង ពាណិជ្ជកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធនិងការដឹកជញ្ជូនបៃតង ទេសចរណ៍បៃតង ថាមពលបៃតង សំណង់និងអគារបៃតង ទូរគមនាគមន៍បៃតង ការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យបៃតង ជំនាញនិងបច្ចេកទេសបៃតង ស្ថាបនាបៃតង កន្លែងធ្វើការងារមានលក្ខណៈបៃតង ទីផ្សារបៃតង ការផ្សព្វផ្សាយផលិតផលបៃតង ការលក់ដូរផលិតផលនិងសេវាកម្មបៃតង ព្រមទាំងលទ្ធកម្មហិរញ្ញវត្ថុបៃតង ឥណទាន ហិរញ្ញវត្ថុនិងពន្ធដារបៃតងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ក្រោយពីបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នា អង្គប្រជុំបានសំណូមពរឲ្យមានការពន្យល់បន្ថែមនូវការប្រើពាក្យបៃតងដូចជា មនុស្សបៃតង មាតាបៃតង យុវជនបៃតង...។ អង្គប្រជុំក៏សំដែងការព្រួយបារម្ភផងដែរអំពីការអនុវត្តផែនការយុទ្ធសាស្ត្រក្នុងរយៈពេល១០ឆ្នាំឲ្យទទួលបានជោគជ័យ។ ក្រៅពីនេះអង្គប្រជុំបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតងនិងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងសម្រាប់រយៈពេល១០ឆ្នាំ។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០១២



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០១២នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➢ ក្នុងឆ្នាំ២០១២ អត្រាអតិផរណាស្មើនឹង ២,៩% (ផែនការប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ៥%)។ តារាងខាងក្រោមបង្ហាញអតិផរណាប្រចាំខែ ២០១០-២០១២ (ដែលជាការឡើងនៃថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន)។

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |

➢ បើពិនិត្យតាមក្រុមទំនិញវិញ បម្រែបម្រួលសន្ទស្សន៍ថ្លៃមានដូចខាងក្រោម៖

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ២០១២ | អត្រារួមចំណែក | អតិផរណាឆ្នាំ២០១១ |
|---|---|---|---|---|
| 0 | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ២,៩% | ១00% | ៥,៥% |
| ១ | ម្ហូបអាហារ | ៣,៣% | ៤៨% | ៦,៦% |
| ២ | ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ២,0% | ១,១% | 0,១% |
| ៣ | សម្លៀកបំពាក់ និងស្បែកជើង | ៤,១% | ៤,២% | ២,៤% |
| ៤ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន ... | ២,២% | ១៣% | ៣,៨% |
| ៥ | គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ៣,៣% | ៣% | ១,៩% |
| ៦ | សុខាភិបាល | -0,៧% | -១,២% | 0,៨% |
| ៧ | ការដឹកជញ្ជូន<br>ក្នុងនោះ ប្រេងសាំង | ៣,២%<br>៥% | ១៣%<br>៨% | ៧,១%<br>១៦% |

| | | | | |
|---|---|---|---|---|
| ៨ | ទូរគមនាគមន៍ | -១,៦% | -០,៦% | ០,៨% |
| ៩ | ការកម្សាន្ត និងវប្បធម៌ | ០,៦% | ០,៦% | -១,៦% |
| ១០ | ការសិក្សា | ២,៤% | ០,៩% | ០,៦% |
| ១១ | ភោជនីយដ្ឋាន | ៤,៧% | ៩% | ៧,៩% |
| ១២ | ទំនិញ និងសេវាកម្មផ្សេងៗ | ៤,៦% | ៣,៥% | ៩,៣% |

⇨ ដូច្នេះការថយចុះនៃអតិផរណាក្រុមម្ហូបអាហារ និងក្រុមការដឹកជញ្ជូន ធ្វើឲ្យអត្រាអតិផរណាសរុបថយចុះពី ៥,៥% ក្នុងឆ្នាំ ២០១១ មកត្រឹមតែ ២,៩% ក្នុងឆ្នាំ២០១២ ។

⇨ មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មានសាច់គោស្រស់ ១៥% និងបន្លែ ៨,៦% ។

➢ **អត្រាប្តូរប្រាក់៖**

⇨ ជារួមអត្រាប្តូរប្រាក់**រៀល ធៀបនឹងរូបិយវត្ថុបរទេស**មានស្ថេរភាព៖

- ប្រាក់រៀលឡើងថ្លៃ ១,១% ធៀបនឹងដុល្លារសហរដ្ឋអាមេរិក
- ប្រាក់រៀលចុះថោក ៣,១% ធៀបនឹងបាតថៃ
- ប្រាក់រៀលឡើងថ្លៃ ០,៥% ធៀបនឹងដុងវៀតណាម។

## ២) ស្ថានភាពថវិកាជាតិ

➢ យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០១២នេះ អនុវត្តបានចំនួន ៧៨១០ ពាន់លានរៀល ស្មើនឹង ៧៣% នៃគម្រោង ក្នុងនោះចំណូលចរន្ត ៧៤៤៤ ពាន់លានរៀល ស្មើនឹង ១០២% នៃគម្រោង ចំណូលមូលធនអនុវត្តបាន ៣៦៦ ពាន់លានរៀល។

➢ បើធៀបនឹងឆ្នាំ២០១១ ចំណូលថវិកាជាតិកើនឡើង ១៧% ដែលក្នុងនោះ ចំណូលចរន្តកើនឡើង ២៣% និងចំណូលមូលធនកើនឡើង ២៣% ។

⇨ការកើនឡើងនៃចំណូលចរន្តបណ្តាលមកពីចំណូលសារពើពន្ធកើនឡើង ១៩% និងចំណូលមិនមែនសារពើពន្ធកើនឡើង ៤% ។

| មុខចំណូល | អនុវត្តគម្រោង | %∆ធៀបនឹងឆ្នាំ២០១១ |
|---|---|---|
| **ចំណូលសារពើពន្ធ** | ១០១% | +១៩% |
| ✓**ពន្ធ និងអាករគយ** | ១០៨% | +១៤% |
| –ពន្ធគយ (របបនាំចូល) | ១០៣% | +១៣% |
| –អាករពិសេសលើរបបនាំចូល | ១០៩% | +១៧% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | ១១៣% | +១៥% |
| –អាករនាំចេញ | ៨០% | -២១% |
| –អាករបន្ថែមលើគេលសិលា | ៩៤% | +៧% |
| ✓**ចំណូលពន្ធដារ** | ១០១% | +២៧% |
| –ពន្ធលើប្រាក់បៀវត្ស | ៩៦% | +២៧% |
| – ពន្ធលើប្រាក់ចំណេញ | ១០០% | +៣៤% |
| – ពន្ធលើឈ្នួលផ្ទះ–ដី | ៩៣% | +២៦% |
| – អាករលើផលរបរ | ៧៨% | +៦% |
| – អាករលើតម្លៃបន្ថែម | ៨៧% | +២៨% |
| – អាករពិសេស | ១០៤% | +១៩% |
| – ពន្ធថវិកាខេត្តរាជធានី | ១៤៩% | +២១% |

| មុខចំណូល | អនុវត្តគម្រោង | %∆ធៀបនឹងឆ្នាំ២០១១ |
|---|---|---|
| **ចំណូលមិនមែនសារពើពន្ធ** | ១០៩% | +៤% |
| ✓នេសាទ | ១០៦% | -៤៦% |
| ✓ រុក្ខាប្រមាញ់ | ១១២% | -៣១% |
| ✓សម្បទានរ៉ែ | ៩៨៧% | +៩០៨% |
| ✓អាកាសចរណ៍ស៊ីវិល | ១១១% | +៤% |
| ✓ ផលទុនទេសចរណ៍ | ៨៣% | +១៩% |
| ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ១២៤% | -៣% |
| ✓អាករស្ថានទូត | ១២៧% | +១៨% |
| ✓ ត្រួតពិនិត្យគុណភាពផលិតផល | ១៤៦% | +២៦% |
| ✓ ជួលរោងចក្រ សហគ្រាស | ៧៨% | -១% |
| ✓ ឯកជនភាវូបនីយកម្ម | ៣៤% | -២% |
| ✓ ការលក់អចលនកម្ម | ៤០១៩១% | -១៣% |

| មុខចំណូល | អនុវត្តគម្រោង | %Δធៀបនឹងឆ្នាំ២០១១ | មុខចំណូល | អនុវត្តគម្រោង | %Δធៀបនឹងឆ្នាំ២០១១ |
|---|---|---|---|---|---|
| ✓ចំណូលសារពើពន្ធផ្សេងៗ | ១០១% | +៥% | | | |
| -ចំណូលពីកាស៊ីណូ | ១០២% | +១៣% | | | |
| -ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | ១៥៧% | -១២% | | | |
| - កម្រៃការគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ៩៦% | +២% | | | |

➢ **ចំណាយថវិកាជាតិ**ក្នុងឆ្នាំ២០១២ អនុវត្តបាន ៦៧៨១ ពាន់លានរៀល ស្មើនឹង ៦៣% នៃគម្រោង ក្នុងនោះ ចំណាយចរន្ត ៥៨០៩ ពាន់លានរៀល ស្មើនឹង ៩៣% នៃគម្រោង និងចំណាយមូលធន ៩៧៣ ពាន់លានរៀល។

➢ បើប្រៀបធៀបឆ្នាំ២០១២ និង២០១១ ចំណាយថវិកាជាតិកើនឡើង ២% ក្នុងនោះចំណាយចរន្តកើនឡើង ៩% ចំណាយមូលធនថយចុះ ២៤%។

➢ ជាលទ្ធផល **តុល្យភាពថវិកាជាតិ**នាឆ្នាំ២០១២ មានអតិរេកចំនួន ១០២៨ ពាន់លានរៀល។ ប៉ុន្តែគួរកត់សម្គាល់ថា៖ តារាងទិន្នន័យថវិការជាតិបង្ហាញតែតួលេខចំណាយមូលធនដែលឆ្លងកាត់រតនាគារជាតិប៉ុណ្ណោះ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➢សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១២ មានសូចនាកររូបិយវត្ថុដូចខាងក្រោម៖

⇨ រូបិយវត្ថុ *M2* មានចំនួន ២៨៥៩២ ពាន់លានរៀល កើនឡើង ២១% ធៀបនឹងឆ្នាំ២០១១។

**សមាសធាតុរូបិយវត្ថុ ឆ្នាំ ២០១២** ( % នៃរូបិយវត្ថុទូទៅ *M2* )




**សមាសធាតុរូបិយវត្ថុ ឆ្នាំ ២០១១**




⇨សមាសធាតុរូបិយវត្ថុមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍។ *M1* ថយចុះពី១៧% ក្នុងឆ្នាំ២០១១ មកនៅត្រឹមតែ ១៤% នៃ *M2* ក្នុងឆ្នាំ២០១២ ក្នុងនោះរូបិយវត្ថុក្រៅធនាគារ១៣% និងប្រាក់បញ្ញើចរន្ត ១% ។

⇨ រូបិយវត្ថុផ្សេងៗកើនឡើងពី ៨៣% ក្នុងឆ្នាំ២០១១ ទៅដល់៨៦% នៃ*M2* ក្នុងឆ្នាំ២០១២ ក្នុងនោះប្រាក់បញ្ញើជារូបិយបណ្ណ ៨៣% និងប្រាក់បញ្ញើមានកាលកំណត់និងសន្សំមានប្រហែល ៣%។ តារាងខាងក្រោមបង្ហាញកំណើនសូចនាកររូបិយវត្ថុធៀបនឹងឆ្នាំមុន (២០០៩-២០១២)។

| | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|
| *M2* | +៣៧% | +២០% | +២១% | +២១% |
| *M1* | +៣០% | +៣% | +២៣% | +២% |
| រូបិយវត្ថុក្រៅធនាគារ | +៣១% | +៣% | +២២% | 0 |
| ប្រាក់បញ្ញើចរន្ត | +១៣% | +៣% | +៥១% | +៥៧% |
| រូបិយវត្ថុផ្សេងៗ | +៣៨% | +២៤% | +២១% | +២៥% |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | +៩៤% | +១៤% | +៣៦% | +៤០% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +៣៧% | +២៤% | +២១% | +២៤% |

⇨ គួរកត់សម្គាល់ថា រូបិយវត្ថុក្រៅធនាគារនៅក្នុងឆ្នាំ២០១២នេះ មិនមានការកើនឡើងទេ រីឯប្រាក់បញ្ញើចរន្ត និងប្រាក់បញ្ញើមានកាលកំណត់និងសន្សំ មានការកើនឡើងគួរឲ្យកត់សម្គាល់។

⇨ រូបិយវត្ថុទូទៅ*M2* មានការកើនឡើងជាលំដាប់។ ក្នុងឆ្នាំ២០១២ *M2* មានចំនួនប្រហែល ៥៥% នៃផសស ប៉ុន្តែ**សមមាត្រ** *M1* ក្នុងផសស មានត្រឹមតែ ៧,៨% ប៉ុណ្ណោះ។

រូបិយវត្ថុ M2 ជាភាគរយនៃផសស




ប្រភព៖ Key indicators for Asia and the Pacific 2012: ADB

➢ ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធ មានចំនួន ៣៤៩៤ លានដុល្លារ កើនឡើង ១៩% ធៀបនឹងឆ្នាំ២០១១។
➢ ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅ**ធនាគារជាតិនៃកម្ពុជា** មានចំនួន ៩៤៤៥ ពាន់លានរៀល កើនឡើង ៣៤% បើធៀបនឹងឆ្នាំមុន។
➢ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ២៣៧៧២ពាន់លានរៀល កើនឡើង ៣៤% ធៀបនឹងឆ្នាំមុន។
➢ ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៣៥៣៩ពាន់លានរៀល កើនឡើង ៣៧% ។

➢ **អត្រាការប្រាក់ប្រចាំឆ្នាំ៖**

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ២០១២* | *អត្រាឆ្នាំ២០១១* | %Δ (២០១២/២០១១) |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,២១% | ៦,២១% | 0 |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,៩១% | ១៦,៩១% | 0 |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,២៨% | ៤,២៨% | 0 |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៥,១៤% | ១៥,១៤% | 0 |
| កម្ចីជារៀលនៅហត្ថកសិករ | ៣៦,0 | ៣៦,0 | 0 |
| កម្ចីជារៀលនៅអម្រឹត | ២៨,២ | ២៨,២ | 0 |
| កម្ចីជារៀលនៅស្ថាបនា | ៣៣,0 | ៣៣,0 | 0 |
| កម្ចីជារៀលនៅប្រាសាក់ | ៣១,៨% | ៣១,៨% | 0 |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➢ ***កសិកម្ម៖***

⇨ ផលិតផលស្រូវនៅកម្ពុជាមានការកើនឡើងជាលំដាប់។ ក្នុងឆ្នាំ២០១២ ផលិតផលស្រូវមានបរិមាណ ៩៣០៦ ពាន់តោន កើនឡើង ៦% បើធៀបនឹងឆ្នាំ២០១១។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (២០០៨-២០១២) ផលិតផលស្រូវកើនជាមធ្យម ៧% ក្នុងមួយឆ្នាំ ។







⇨ ក្នុងឆ្នាំ ២០១២ ការដាំស្រូវទាំងពីររដូវបានធ្វើលើផ្ទៃដីចំនួន ២៩៧១ពាន់ហិកតា លើសឆ្នាំ២០១១ ចំនួន ២០៤ពាន់ហិកតា។ ចំណែកឯទិន្នផលស្រូវជាមធ្យមទាំងស្រូវប្រាំងទាំងស្រូវវស្សាក្នុងឆ្នាំ ២០១២ ស្មើនឹង ៣,១៣តោន/១ហិកតា។

⇨ ផលិតផលកៅស៊ូ ក៏មានការកើនជារៀងរាល់ឆ្នាំដែរ។ ក្នុងឆ្នាំ២០១២ ផលិតផលកៅស៊ូមានចំនួន ៦៤,៥ ពាន់តោន កើនឡើង ២៦% ធៀបនឹងឆ្នាំ ២០១១ ផ្ទៃដីចៀរជ័រមានចំនួន ៥៥,៤ ពាន់ហិកតា និងផ្ទៃដីដាំដុះសរុបមាន ២៨០,១ ពាន់ហិតា។

⇨ ផលិតកម្មនេសាទឆ្នាំ២០១២ មានចំនួន **៦៦២ ពាន់តោន**កើនឡើង ១៣%ធៀបនឹងឆ្នាំ២០១១។

➢ ***ឧស្សាហកម្ម៖***

⇨ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣២៧០ GWh កើនឡើង ២៦% ។ ក្នុងនោះ វារីអគ្គិសនីមានចំនួន៥១២,៥ GWh កើនឡើង ៩០០%។

⇨ផលិតកម្មវាយនភណ្ឌនិងស្បែកជើងសម្រេចបាន ៤៣៥៧ លានដុល្លារ កើនឡើង១០%។ ជាទូទៅផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានទំហំធំនៅឆមាសទី២។

⇨ទឹកស្អាតផ្គត់ផ្គង់ដោយរដ្ឋាករទឹកមានចំនួន ១៥៧ លានម³ កើនឡើង ១៣% ។

⇨ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម៖**

| *ប្រភេទ* | *ចំនួន* : ២០១២ | *ចំនួន*: ២០១១ | %∆ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ៩០៨ | ៧០៦ | +២៩% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ២០២ | ១០៨ | +៨៧% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២១៤ | ២៥៣ | -១៥% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៥៤ | ២១៣ | -២៨% |

⇨**សំណង់ (ការអនុញ្ញាត)៖**

▪ ការអនុញ្ញាតឲ្យសាងសង់ឆ្នាំ២០១២ មានទឹកប្រាក់ស្មើនឹង ២១១០ លានដុល្លារកើនឡើង ៦៧% ធៀបនឹងឆ្នាំ២០១១។

| *ប្រភេទសំណង់* | ពាន់ម$^2$:២០១២ | ពាន់ម$^2$:២០១១ | % Δ |
|---|---|---|---|
| លំនៅឋាន | ២៦៨២ | ២០៥១ | +៣១% |
| ឧស្សាហកម្ម | ២០០៦ | ១៣២៤ | +៥២% |
| ពាណិជ្ជកម្ម | ១១៦៦ | ៣៣៤ | +២៤៩% |
| ទេសចរណ៍ | ៣៨៦ | ១២៨៧ | -៧០% |
| … | | | |
| អនុញ្ញាតសរុប | ៦៥២៨ | ៥២៥៨ | +២៤% |

▪ ក្នុងការអនុញ្ញាតឆ្នាំ២០១២នេះ៖ សំណង់ដែលពេញនិយមមាន លំនៅឋាន (៤១% នៃផ្ទៃក្រឡាសរុប) ឧស្សាហកម្ម (៣១% នៃផ្ទៃក្រឡាសរុប) និងពាណិជ្ជកម្ម (១៨% នៃផ្ទៃក្រឡាសរុប)។

**▪ការងារ៖**

| *ប្រភេទ* | ២០១២ (នាក់) | ២០១១ (នាក់) | %Δ |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ៣០៦២៧ | ៣៣១៦៥ | –៨% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៥២៩៨៤ | ៣៩០៧៣ | +៣៦% |
| អ្នកទទួលបានការងារក្នុងប្រទេស | ២៦២៨២ | ១៧៨១១ | +៤៨% |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៦៧០២ | ២១ ២៦២ | +២៦% |

▪ **វិនិយោគ៖** គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./ក.អ.ក. ក្នុងឆ្នាំ២០១២ (ថ្មី និងពង្រីក) មានចំនួន **២១៨** គម្រោង។ ជាទុនវិនិយោគមានទឹកប្រាក់ **២៩៦៦** លានដុល្លារ និងអាចផ្តល់ការងារបាន **៣៣៤** ពាន់នាក់។

| *ប្រភេទ* | *២០១២* | *២០១១* | %Δ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ២៩៦៦ | ៨០៦៩ | -៦៣% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៥៥៧ | ៧៨៥ | -២៩% |
| វិស័យឧស្សាហកម្ម | ១៤៨៩ | ៣៥៦៨ | -៥៨% |
| វិស័យទេសចរណ៍ | ៦៩២ | ៦៦៧ | +៤% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២២៨ | ២៧៨០ | -៩២% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ២១៨ | ១៩១ | +១៤% |
| **ចំនួនពលករ (ពាន់នាក់)** | ៣៣៤ | ២១៦ | +៥៥% |

**▪*សេវាកម្មនិងទេសចរណ៍៖***

**➢ការចុះបញ្ជីនិងលុបចេញពីបញ្ជី**

| *ប្រភេទ* | ២០១២ (*ចំនួន*) | ២០១១(ចំនួន) | %Δ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣៣៨៦ | ៣០៩១ | +១០% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៥៥ | ៣៨ | +៤៥% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ២៤៧៨ | ៣១២៤ | -២១% |

**➢ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ)មានចំនួន ៥៣៣៨ពាន់តោនកើនឡើង២៣%។ ក្នុងនោះ៖

| *ប្រភេទ* | ២០១២ (ពាន់តោន) | ២០១១ (ពាន់តោន) | %Δ |
|---|---|---|---|
| ផែភ្នំពេញ | ១៦២៨ | ១៥៦១ | +៤% |
| ផែកំពង់សោម | ២៥៧២ | ២១៦១ | +១៩% |
| ផែស្រែអំបិល និងកោះកុង | ៤៩៥ | ៥៥៣ | -១១% |
| ផែឧកញ៉ាម៉ុង | ៦៣៤ | ១៦៩ | +២៧៥% |

➢អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍

| *ប្រភេទ* | ២០១២ (ពាន់នាក់) | ២០១១ (ពាន់នាក់) | %Δ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១០១ | ៨៩ | +១៣% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៨៣ | ១៤៤ | +២៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣៩៩៩ | ៣៤២៥ | +១៧% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៧៦៨ | ៧០៩ | +៨% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ៣៥៨៤ | ២៨៨២ | +២៤% |
| ✓តាមផ្លូវអាកាស | ១៧២២ | ១៤៧៩ | +១៦% |
| ✓ តាមផ្លូវគោក និងទឹក | ១៨៦២ | ១៤០២ | +៣៣% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

- យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០១២ មានចំនួន៣០៤៥៤ ពាន់លានរៀលកើនឡើង ១៩% បើធៀបនឹងឆ្នាំ ២០១១។ ក្នុងនោះ៖

| **មានការថយចុះ** | **មានការកើនឡើង** | |
|---|---|---|
| ប្រេងសាំង -៣% | ប្រេងម៉ាស៊ូត +១១% | អង្ករ +១៧២៣% |
| ប្រេងខ្មៅ -៧% | ឧស្ម័ន +១៩% | ផ្លែឈើនិងបន្លែ +២៨% |
| គ្រឿងអេឡិចត្រូនិច -១៦% | អគ្គិសនីនាំចូល +១៥% | ជីនិងថ្នាំកសិកម្ម +១៧% |
| ត្រាក់ទ័រនិងគោយន្ត -៨% | ដែកសំណង់ +៦៤% | ស្ករស +៤៨% |
| ប៊ីចេង -៥% | ស៊ីម៉ង់ +៣៨% | ភេសជ្ជៈ +៧៦% |
| | រថយន្តសរុប (ជាសាច់ប្រាក់) +៣២% | ប្រេងឆា +១២% |
| | ម៉ូតូ +៥៩% | ការនាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិ |
| | បារី +៣៦% | យោគ +៦% |

- **ការនាំចេញ**ឆ្នាំ២០១២ មានចំនួន ២២៤៨១ ពាន់លានរៀលកើនឡើង ១២% ធៀបនឹងឆ្នាំ២០១១។ក្នុងនោះ៖

| *ទំនិញ* | %Δធៀបនឹង –២០១១ | *ទំនិញ* | %Δធៀបនឹង –២០១១ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | –៣៩% | អង្ករ | +៩% |
| វាយនភណ្ឌនិងស្បែកជើង | +៨% | ផលិតផលនេសាទ | –១២% |
| កៅស៊ូ | +១៩% | | |

- ក្នុងឆ្នាំ២០១២ *ឱនភាពជញ្ជីងពាណិជ្ជកម្ម*មានចំនួន *៧៩៧៣ ពាន់លានរៀល ស្មើនឹង ១៩៩៣ លានដុល្លារ។*

ឱនភាពជញ្ជីងពាណិជ្ជកម្មតែងតែមានទំហំធំក្នុងឆមាសទី១។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆ្នាំ២០១២នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | បម្រែបម្រួលធៀបនឹងឆ្នាំ ២០១១ | ផ្សេងៗ |
|---|---|---|
| ១. ថ្លៃសាច់គោ | +១៥% | បញ្ហាតម្រូវការ និងការផ្គត់ផ្គង់ |
| ២. ថ្លៃបន្លែ | +៩% | បញ្ហាតម្រូវការ និងការផ្គត់ផ្គង់ |
| ៣. រូបិយវត្ថុក្រៅធនាគារ | 0 | ជាប្រាក់រៀលសរុបដែលវិលនៅក្នុងចរាចរណ៍ |
| ៤. ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | -១២% | ជាមុខចំណូលសារពើពន្ធផ្សេងៗ |
| ៥. ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | -១៥% | — |
| ៦. ឧស្សាហកម្មធុនតូច និងសប្បកម្ម (បន្ត) | -២៨% | — |

ក្នុងខែវិច្ឆិកា ឆ្នាំ២០១២នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលថវិកាជាតិ | -៩% | -៤% | នេះជាលើកទី១ក្នុងឆ្នាំ២០១២ ដែលចំណូលថវិកាជាតិប្រចាំខែទាបជាងចំណូលខែដូចគ្នាឆ្នាំមុន។ |
| ២ | ក្រុមហ៊ុនបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ១៣%- | ១-៤% | — |
| ៣ | ទុនវិនិយោគអនុញ្ញាតដោយ ក.ក.អ. | ៩២%- | ៩-៤% | — |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

*អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖*

១) សាច់គោនិងបន្លែជាមុខទំនិញពីរដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់ក្នុងឆ្នាំ២០១២។ មូលហេតុសំខាន់គឺការផ្គត់ផ្គង់ក្នុងស្រុកមានកម្រិតទាប។ បច្ចុប្បន្នកម្ពុជាពឹងផ្អែកលើការនាំចូលបន្លែ និងផ្លែឈើពីប្រទេសជិតខាង ប្រហែលពាក់កណ្ដាលនៃតម្រូវការសរុប។

២) ការអនុវត្តចំណូលថវិកា ធៀបនឹងគម្រោងមានលក្ខណៈល្អប្រសើរក្នុងឆ្នាំ២០១២។

៣) ក្នុងឆ្នាំ២០១២ គម្រោងវិនិយោគអនុញ្ញាតដោយក.អ.ក មានការកើនឡើង ប៉ុន្តែតម្លៃនៃការវិនិយោគមានការថយចុះ។ តួលេខវិនិយោគឆ្នាំ២០១២នេះបង្ហាញថា លំហូរទៅក្នុងវិស័យកសិកម្មមានចំនួនតិចជាងវិស័យដ៏ទៃទៀត រីឯវិនិយោគមកពីប្រទេសជប៉ុនមានការកើនឡើង។

៤) កម្ពុជាមានឱនភាពជញ្ជីងពាណិជ្ជកម្មខ្ពស់គួរឲ្យកត់សម្គាល់។

*សេចក្ដីសន្និដ្ឋាន៖*

១) អត្រាអតិផរណាឆ្នាំ២០១២មានកម្រិតទាបត្រឹមតែ ២,៩% ប៉ុណ្ណោះ។ មូលហេតុសំខាន់គឺ អតិផរណានៃក្រុមម្ហូបអាហារមានការធ្លាក់ចុះ។ ទន្ទឹមនឹងនោះ រូបិយវត្ថុក្រៅធនាគារ ដែលជាប្រាក់រៀលនៅក្នុងចរាចរនាឆ្នាំ២០១២នេះ ស្ថិតនៅថេរ ដែលនាំឲ្យមានការរឹតត្បិតក្នុងការប្រើប្រាស់ប្រាក់រៀល។

២) យើងក៏កត់សម្គាល់ដែរថា ប្រាក់បញ្ញើជារៀលនៅក្នុងធនាគារមានការកើនឡើង ទាំងប្រាក់បញ្ញើចរន្ត និងប្រាក់បញ្ញើមានកាលកំណត់ នេះបង្ហាញថាតម្រូវការលើប្រាក់រៀលមានការកើនឡើង ។

៣) ឱនភាពខ្ពស់នៃជញ្ជីងពាណិជ្ជកម្ម មានលក្ខណៈសមស្របនឹងដំណាក់កាលរីកចម្រើនរបស់សេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន ដែលកំពុងមានតម្រូវការខ្ពស់លើទំនិញមូលធនសម្រាប់ផលិតកម្មក្នុងស្រុក។ បើយើងពិនិត្យមើលសមតុល្យទំនិញនិងសេវាប្រើប្រាស់នោះ ជញ្ជីងពាណិជ្ជកម្មនឹងមិនគួរឲ្យកត់សម្គាល់ទេ។

## សកម្មភាពផ្សេងៗរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
## ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០២/១៣<br>ម៉ោង ០៦:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីដង្ហែព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"។ |
| ២ | ០៤/០២/១៣<br>ម៉ោង ១៦ : ២០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតន កោដ្ឋ" នៅវាលព្រះមេរុ។ |
| ៣ | ០៥/០២/១៣<br>ម៉ោង ០៨ :៣០នាទី | ចូលរួមជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានកាយវិទ្ធិជាតិកម្ពុជា ក្នុងពិធីជួបសំណេះសំណាល ជាមួយឯកឧត្តម **ហេ ហ្វម៉ាប៊ីណៃ** អនុប្រធានប្រធានាធិបតីហ្វីលីពីន និងជាប្រធានកាយវិទ្ធិសាធារណរដ្ឋហ្វីលីពីន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៧/០២/១៣<br>ម៉ោង ០៧ :៣០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីដង្ហែព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"។ |
| ៥ | ០៧/០២/១៣<br>ម៉ោង ១៥ :៣០នាទី | ដឹកនាំកិច្ចប្រជុំផ្តល់យោបល់ស្តីពីតម្រូវការប្រើប្រាស់ និងគំរូប្លង់ដំបូងអគារសន្តិសុខ នៃទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៨/០២/១៣<br>ម៉ោង ១០ :៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **សេង ហួរលាង** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១៣/០២/១៣<br>ម៉ោង ០៨ :៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ប្រចាំឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១៣/០២/១៣<br>ម៉ោង ១៦ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គាំទ្រកិច្ចសហប្រតិបត្តិការបោស សំអាតមីន ក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | ១៤/០២/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅបរិវេណវត្តស្វាយពពែ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ |
| ១០ | ១៤/០២/១៣<br>ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ អគ្គលេខាធិការដ្ឋានអាកាសចរស៊ីវិល នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១៥/០២/១៣<br>ម៉ោង ០៩:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការ អភិវឌ្ឍបៃតងសម្រាប់រយៈពេល១០ឆ្នាំ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងកិច្ចការពាររូបភាពប្រាសាទនានា នៃរមណីយដ្ឋានអង្គរ។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៨/០២/១៣<br>ពេញមួយថ្ងៃ | ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១២ និងលើកទិសដៅការងារឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៩/០២/១៣<br>ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១២ និងលើកទិសដៅការងារឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនា បតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៤ | ១៩/០២/១៣<br>ម៉ោង ១៦:៣០នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការ អភិវឌ្ឍបៃតងសម្រាប់រយៈពេល១០ឆ្នាំ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងកិច្ចការពាររូបភាពប្រាសាទនានា នៃរមណីយដ្ឋានអង្គរ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

### ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៥ | ២០/០២/១៣<br>ម៉ោង ០៩ :០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ Japan Airport Consultants តំណាងក្រសួងដែនដីហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងទេសចរណ៍របស់ប្រទេសជប៉ុន និងតំណាងអគ្គលេខាធិការដ្ឋានអាកាសចរស៊ីវិល នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២០/០២/១៣<br>ម៉ោង ១០:៣០នាទី | ជួបប្រជុំពិភាក្សាការងារដែលពាក់ព័ន្ធទៅនឹងអាកាសយានដ្ឋានទាំង៣ ជាមួយឯកឧត្តម **ផេង សុទិដ្ឋារោ** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | ២០/០២/១៣<br>ម៉ោង ១៧:០០នាទី | ចូលរួមក្នុងពិធីបញ្ចុះបឋមសីលាដើម្បីកសាងព្រះបរមរូប ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសួនច្បារខាងកើតវិមានឯករាជ្យ។ |
| ១៨ | ២១/០២/១៣<br>ម៉ោង ១៨ : ០០<br>នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបុណ្យ CAMBODIA JAPAN FESTIVAL លើកទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (វិទ្យាស្ថានភាសាបរទេស IFL អគារអង្គរគីសូណា)។ |
| ១៩ | ២២/០២/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធី នៃការដាក់ឈ្មោះផ្លូវ ឬលេខផ្លូវ និងការកែប្រែ ឈ្មោះផ្លូវ ឬលេខផ្លូវ។<br>៣-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិ លើ៖<br>៣.១-កិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនផ្លូវសមុទ្រ រវាងរដ្ឋាភិបាល នៃប្រទេសជាសមាជិកអាស៊ាន និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន។<br>៣.២-កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ។<br>៣.៣-ពិធីសារទី៦ ស្តីពីព្រំដែនផ្លូវដែក និងស្ថានីយ៍ប្តូរខ្សែរថភ្លើងសម្រាប់ការអនុវត្តកិច្ចព្រម ព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលទំនិញឆ្លងកាត់។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

### ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ២០ | ២៦/០២/១៣ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិ ព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ២១ | ២៦/០២/១៣ ម៉ោង ១៥:៣០នាទី | ចូលរួមជុំការងារស្រុកព្រៃកប្បាស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅបាទី។ |
| ២២ | ២៧/០២/១៣ ម៉ោង ០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោកស្រី **ឆាយ ចិន្តា** អ្នកសម្របសម្រួលផ្នែកវប្បធម៌ នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | ២៧/០២/១៣ ម៉ោង ១៤:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅសាលសន្និសីទចតុមុខ។ |
| ២៤ | ២៨/០២/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងវេទិកាថ្នាក់តំបន់លើកទី៤ ស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |
| ២៥ | ២៨/០២/១៣ ម៉ោង ១៥:៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ២៦ | ២៨/០២/១៣ ម៉ោង ១៩:៣០នាទី | ចូលរួមពិសាភោជនាហារពេលល្ងាចជាមួយ លោក Dominique Mas ទីប្រឹក្សាទី១ នៃស្ថានទូតប្រទេសបារាំង និងលោកស្រី នៅរាជធានីភ្នំពេញ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៣/០២/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គាំទ្រកិច្ចសហប្រតិបត្តិការបោះសំអាតមីនក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យសម្រាប់ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៩/០២/១៣<br>ម៉ោង ១៦:៣នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍបៃតងសម្រាប់រយៈពេល១០ឆ្នាំ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងកិច្ចការពាររូបភាពប្រាសាទនានា នៃរមណីយដ្ឋានអង្គរ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២១/០២/១៣<br>ម៉ោង ១៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យ Cambodia Japan Festival លើកទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ |
| ៤ | ២៨/០២/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងវេទិកាថ្នាក់តំបន់លើទី៤ ស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣

## ឯកឧត្តម ឌុយ ឆៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៣/២១/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គាំទ្រកិច្ចសហប្រតិបត្តិការបោះសំអាតមីនក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៩/០២/១៣<br>ម៉ោង ១៦:៣នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងសម្រាប់រយៈពេល១០ឆ្នាំ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងកិច្ចការពាររូបភាពប្រាសាទនានានៃរមណីយដ្ឋានអង្គរ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២៦/០២/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៤ | ២៨/០២/១៣<br>ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៣

## ឯកឧត្តម ម៉ាន់ តិរុណា អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៣/០២/១៣<br>ម៉ោង ១៦:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គាំទ្រកិច្ចសហប្រតិបត្តិការបោះសំអាតមីនក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ២០១៣ ក្រោមអធិបតី ភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ២១/០២/១៣<br>ម៉ោង ១៨:០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យ Cambodia Japan Festival លើកទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ |
| ៣ | ២២/០២/១៣<br>ម៉ោង ០៨:៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការដាក់ឈ្មោះផ្លូវ ឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវ ឬលេខផ្លូវ។<br>៣-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៣.១-កិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនផ្លូវសមុទ្រ រវាងរដ្ឋាភិបាល នៃប្រទេសជាសមាជិកអាស៊ាន និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។<br>៣.២-កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលការដឹកជញ្ជូនអន្តររដ្ឋ។<br>៣.៣-ពិធីសារទី៦ ស្តីពីព្រំដែនផ្លូវដែក និងស្ថានីយ៍ប្តូរខ្សែរថភ្លើង សម្រាប់ការអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការសម្រួលទំនិញឆ្លងកាត់។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៤ | ២៨/០២/១៣<br>ម៉ោង ០៨:០០ នាទី | ចូលរួមជាកិត្តិយសក្នុងវេទិកាថ្នាក់តំបន់លើទី៤ ស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅៈ | **ឯកឧត្តម គីម សយសាម៉ាឡែន** | អនុប្រធាន ក.ស.វ. |
| និពន្ធនាយកៈ | **ឯកឧត្តម ហ៊ាន់ តិរុណា** | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទៈ | **ឯកឧត្តម អេង រត្នមុនី** | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ចៈ | **ឯកឧត្តម ម៉ម សារិទ្ធ** | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយៈ | **លោក ម៉ក់ ឆារ៉ា** | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួលៈ | **លោក សយ វាស្នា** | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូបៈ | **លោក មុត កក្កដា** | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខៈ ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខៈ ០២៣ ២១១ ៩៤៣

E-mail: veasna@live.in